36/07

# ព្រះរាជាណាចក្រកម្ពុជា

សាលាឧទ្ធរណ៍ ជាតិ សាសនា ព្រះមហាក្សត្រ

## នាមប្រជារាស្ត្រខ្មែរ

រឿងក្តីរដ្ឋប្បវេណី សាលាឧទ្ធរណ៍ភ្នំពេញ

លេខ ២៣៣/២១-៦-១២

**សាលដីកា** បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទីបួន ខែកញ្ញា ឆ្នាំ២០១២

លេខ ២៧ក្រ៧-ឃ-ចុ: **សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ:**

ថ្ងៃទី ០៤-៩-២០១២ លោក [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

លោក [redacted]

-ដើមចោទឈ្មោះ: [redacted] **ស៊ុម៉ាលី** ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរ មន្ត្រីរាជការ មានទីលំនៅភូមិ១ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ (ចុងបណ្តឹងឧទ្ធរណ៍)។ មានមេធាវីតំណាងដោយអណត្តិឈ្មោះ: [redacted] ធីតា, [redacted] លីឡា។

-ចុងចម្លើយឈ្មោះ: [redacted] **ស៊ីអៀង** ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ មុខរបរ ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា មានទីលំនៅផ្លូវលេខ ៥២៨ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ(ដើមបណ្តឹងឧទ្ធរណ៍)។ មានមេធាវីតំណាងដោយអណត្តិឈ្មោះ: [redacted]

**កម្មវត្ថុបណ្តឹង:**

-សុំបើកច្រកផ្លូវចេញ-ចូល ទំហំទទឹង ១០ម ទៅកាន់ដីរបស់ខ្លួនតាមលំនាំដើមទៅកាន់ផ្លូវលេខ ២០០៤។

-ឲ្យចុងចម្លើយឈ្មោះ: [redacted] ស៊ីអៀង ប្រគល់ដីទំហំ ៥០១ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវលេខ ២០០៤ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឲ្យទៅខ្លួនដើម្បីបង្គ្រប់ដីទំហំសរុបចំនួន ៤០០០ ម៉ែត្រក្រឡា គ្រប់គ្រងជាកម្មសិទ្ធិវិញ។

-ឲ្យចុងចម្លើយរ៉ាប់រងការចំណាយផ្សេង ក្នុងការបើកច្រកចេញ-ចូលវិញ។

-ឲ្យចុងចម្លើយរ៉ាប់រងពន្ធលើពាក្យបណ្តឹង និងពន្ធលើប្រាក់ប្រដាប់ក្តី

១៦៥

តុលាការក្រៅពន្ធ។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

តាមពាក្យបណ្តឹងចុះថ្ងៃទី ៣០-១២-២០១០ និងពាក្យបណ្តឹងបន្ថែម ចុះថ្ងៃទី ២៦-៥-២០១០ របស់ដើមចោទឈ្មោះ [redacted] សុម៉ាលី បានបញ្ជាក់ថា កាលពីមុនដីទំហំ១០ម ស្ថិតនៅភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៤ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ គឺជាភ្លឺភ្លោះ "ផ្លូវដើរ" ស្ថិតនៅខាងផ្នែកខាងកើតដីខ្លួនដែលប្រជាពលរដ្ឋដែលនៅជុំវិញដីខ្លួន ហើយនៅឆ្នាំ២០០៦ ចុងចម្លើយបានចាក់ដីលុបភ្លឺភ្លោះនោះធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ព្រមទាំងធ្វើរបងបិទផ្លូវ ធ្វើឲ្យខ្លួនមិនអាចចេញចូលទៅកាន់ដីនោះបាន។ ករណីនេះខ្លួនបានប្តឹងទៅអាជ្ញាដែនដី និងសុរិយោដីរាជធានីភ្នំពេញរហូត តែពុំឃើញមានដំណោះស្រាយ ម៉្យាងទៀតតាមការចុះពិនិត្យទីតាំងដីទំនាស់ជាក់ស្តែងកាលពីថ្ងៃទី ០៥-៥-២០១១ ឃើញថាដីរបស់ខ្លួនបាត់បង្គោលព្រំដីអស់ និងឃើញដីខ្លួនរួមតូចជាងមុន ហើយខ្លួនអញ្ជើញជំនាញសុរិយោដីចុះទៅវាស់តាមលក្ខណៈបច្ចេកទេសឃើញថា ដីខ្លួនមានទំហំ ៤០០០ម៉ែត្រក្រឡា បែរជានៅសល់ទំហំ ៣៤៩៩ ម៉ែត្រក្រឡា បាត់អស់ទំហំ៥០១ ម៉ែត្រក្រឡា។

### ១-<u>ការអះអាងរបស់ដើមចោទ</u>

-ឈ្មោះ [redacted] សុម៉ាលី "អវត្តមាន"

-មេធាវី [redacted] តំណាងដោយអណត្តិឲ្យឈ្មោះ [redacted] សុម៉ាលី បានថ្លែងថា តាមពិតទៅនៅក្នុងដំណើរការនីតិវិធីតុលាការបានចេញដីកាបង្គាប់ឲ្យផ្តល់ភស្តុតាង មានឯកសារជាភស្តុតាងត្រឹមត្រូវ ហើយភាគីខ្លួនបានទទួលនឹងដាក់ភស្តុតាងតាមដីកាបង្គាប់ឲ្យផ្តល់ភស្តុតាងរបស់ចៅក្រមសាលាដំបូងតាមនីតិវិធី ហើយនៅក្នុងកំណត់ហេតុនីតិវិធីត្រៀមភាគីលោក [redacted] ស៊ូអៀង មានមេធាវីតំណាងក្នុងនោះក៏មានលោក [redacted], [redacted] ដែរ និងលោក [redacted] ប៉ូលី បានទទួលដីកាបង្គាប់ឲ្យផ្តល់ភស្តុតាងនេះពីតុលាការរួចហើយ ដែលមានឯកសារនៅក្នុងសំណុំរឿង ដូច្នេះការដែលលើកឡើងថាមិនបានទទួលដំណឹងពីការផ្តល់ភស្តុតាងពីតុលាការឲ្យដាក់នោះមិនត្រឹមត្រូវទេ ហើយពាក់ព័ន្ធនឹងនីតិវិធីនេះលោក [redacted] ប៉ូលី គាត់មានវត្តមានរហូតតាំងពីនីតិវិធីត្រៀមជាហូរហែរ ក្នុងនាមគាត់ជាមេធាវីតំណាងដោយអណត្តិគាត់មានសិទ្ធិដាក់ភស្តុតាង ឯកសារនានាដើម្បីការពារផលប្រយោជន៍ឲ្យកូនក្តីរបស់គាត់ ហើយក្នុងរឿងនេះមានមេធាវីដល់ទៅពីររូបមិនមែនតែមួយរូបទេ និងរាល់ការដំណើរការជាហូរហែរមកពុំមានការដកពាក្យរបស់លោក [redacted] ប៉ូលី ឈប់ការពារនោះដែរ គឺនៅការពារដដែល គ្រាន់តែពេលសវនាការគាត់មិនចូលរួមជាហេតុផលរបស់គាត់។ ពាក់ព័ន្ធនឹងការស្នើសុំនូវឯកសារច្បាប់ដើមពីកូនក្តីខ្លួននៅក្នុងលិខិតផ្ទេរសិទ្ធិពីការធ្វើអំណោយផ្តាច់ នៅពេលធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់ហើយ ក្រុមប្រឹក្សាអត់បានប្រកាសសាលក្រមភ្លាមទេ បានលើកពេលនិងស្នើសុំឲ្យភាគីខាងខ្លួនយកឯកសារច្បាប់ដើមទៅតាមការស្នើសុំរបស់មេធាវីលោក [redacted] ដើម្បីចង់មើល ភាគីខ្លួនបានយកសារដើមដាក់ជូនធ្វើការពិនិត្យមើល ឃើញថាខាងខ្លួនពុំមានអ្វីបិទបាំងទេ ជាក់ស្តែងមុនពេលប្រកាសក៏ខាងខ្លួននៅតែរក្សាឯកសារច្បាប់ដើមនៅតុលាការទៀតមិនទាន់បានដកយកមកវិញទេ ពេល



Scanned with CamScanner

នោះក៏មានវត្តមានភាគីលោកមេធាវីចូលរួមស្តាប់ការប្រកាសដែរ ក៏អាចមើលនៅពេលហ្នឹងបានដែរ។ ពាក់ព័ន្ធ នឹងអង្គហេតុនៃការទាមទាររបស់កូនក្តីខ្លួន ដីដែលកូនក្តីខ្លួនបានអះអាងថា គាត់បានកាន់កាប់និងគ្រប់គ្រងមានទំហំ ៨០អា ជាប្រភេទដីស្រែពីមុនមក ហើយជុំវិញបរិវេណដីគាត់ក៏ជាដីស្រែដែរ ឃើញថាដីស្រែខណ្ឌទៅដោយភ្លឺមិនអាចទំលាយចូលគ្នាទេ និងជាប់នៅផ្នែកខាងកើតមានភ្លឺភ្លោះៗ សំរាប់ដើរចេញចូលទៅកាន់ស្រែរបស់ប្រជាពលរដ្ឋដែលបានធ្វើស្រែនៅពេលនោះ ហើយភ្លឺភ្លោះមានស្ថានភាពធំទូលាយក្នុងការដឹកជញ្ជូនផលស្រូវមកកាន់ផ្លូវ២០០៤។ ក្រោយមកលោក [redacted] ស៊ូអៀង បានទិញដីស្រែដែលព័ទ្ធជុំវិញដីរបស់កូនក្តីខ្លួនអស់ទៅគាត់បានធ្វើការកែប្រែស្ថានភាពទីតាំងពីមុនហ្នឹង បានចាក់ដីលុបភ្លឺដែលព័ទ្ធជុំវិញហ្នឹងអស់ហើយៗ ស្នាមភ្លឺភ្លោះក៏បានបាត់ដែរ។ ពាក់ព័ន្ធភ្លឺស្រែ ភ្លឺភ្លោះដែលរូបថតលើអាកាសមកមានច្បាស់នូវផែនទី ពិតជាមានស្នាមភ្លឺស្រែ និងភ្លឺភ្លោះដែលនៅស្រែនីមួយៗ ពិតប្រាកដមែន ដូច្នេះការលើកឡើងថាដីរបស់កូនក្តីខ្លួនគ្មានច្រកសំរាប់ចេញចូលនោះ តើពេលធ្វើស្រែពេលនោះដឹកផលចេញតាមណា មានសាក្សីជាអ្នកធ្វើស្រែដែលបានប្រវាស់ជាមួយកូនក្តីខ្លួនហ្នឹងគាត់បានមកឆ្លើយបំភ្លឺដែរ ហើយជាក់ស្តែងអ្នកចែកដីឲ្យបានធ្វើលិខិត និងឆ្លើយបំភ្លឺថា ដីគាត់មានព្រំប្រទល់ជាប់ហ្នឹងមានភ្លឺស្រែសំរាប់ចេញចូល និងផ្នែកខាងកើតមានភ្លឺភ្លោះសំរាប់ចេញចូលពិតប្រាកដមែន ហើយសាក្សីទាំងអស់ហ្នឹងសុទ្ធតែជាអ្នកបែងចែកដីសម័យកាលហ្នឹង និងមានដីនៅជាប់ព្រំប្រទល់កូនក្តីរបស់ខ្លួន និងជាក់ស្តែងអ្នកធ្វើស្រែលើដីរបស់កូនក្តីខ្លួន នេះបញ្ជាក់ឲ្យឃើញថាភ្លឺស្រែសំរាប់ចេញចូលដីរបស់កូនក្តីខ្លួនមានពិតប្រាកដមែន ប៉ុន្តែត្រូវបានភាគីចុងចម្លើយចាក់ដីលុប កែប្រែស្ថានភាពដើម ហើយបច្ចុប្បន្នគាត់បានធ្វើផ្លូវបេតុងមួយដែលស្របជាប់ព្រំប្រទល់ផ្នែកខាងលិចដីកូនក្តីខ្លួនហ្នឹង ត្រូវបានធ្វើរបងបាំងជិតខ្ពស់ដែលបណ្តាលឲ្យកូនក្តីខ្លួនចូលទៅដីរបស់គាត់បានទេ ហើយបរិវេណបានធ្វើជិតអស់ សំណាញ់ព័ទ្ធជុំវិញ រីឯស្ថានភាពដីកូនក្តីខ្លួនដូចជាស្រះអញ្ចឹងព្រោះគាត់ចាក់ដីជុំវិញអស់ហើយៗ សាលាដំបូងបានចុះទៅពិនិត្យដោយផ្ទាល់ដោយសារគាត់ចាក់ដីស្រែឲ្យខ្ពស់ដីដែលចាក់ហ្នឹងបានហូរចូលមកក្នុងដីកូនក្តីខ្លួនជុំវិញ ធ្វើឲ្យដីរបស់កូនក្តីខ្លួនរួមតូចជាហេតុធ្វើឲ្យបាត់អស់ទំហំ ៨០២ម² ដូចលិខិតជំនាញបានគូសមកហ្នឹង ហើយកូនក្តីខ្លួនបានទាមទារទំហំដីដែលបានបាត់ហ្នឹង។ ការទាមទារនេះធ្វើទៅតាមលិខិតធ្វើអំណោយផ្តាច់ និងបង្កាន់ដៃទទួលពាក្យដែលបញ្ជាក់អំពីទំហំដីដែលកូនក្តីខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៩០មក ពាក់ព័ន្ធនឹងច្រកកូនក្តីខ្លួនសុំរក្សាសិទ្ធិសុំបើកច្រកផ្លូវហ្នឹង ប៉ុន្តែដោយសាលាដំបូងពិនិត្យឃើញថាបច្ចុប្បន្នផ្លូវមានហើយ ដើម្បីឲ្យមានភាពងាយស្រួលទីតាំងកន្លែងហ្នឹងជាផ្លូវស្រាប់ដែរក៏បានសម្រេចបើកច្រកផ្លូវហ្នឹងសំរាប់ឲ្យកូនក្តីខ្លួនចេញចូលទៅកាន់ដីរបស់គាត់ និងមកកាន់ផ្លូវ២០០៤។ រាល់ការសម្រេចសេចក្តីរបស់សាលាដំបូងតាមអំណាចសាលក្រមលេខ ០២ក្រ''យ''ចុះថ្ងៃទី ១០-០២-២០១២ មានភាពត្រឹមត្រូវ និងយុត្តិធម៌ហើយ សុំក្រុមប្រឹក្សាមេត្តាតម្កល់សាលក្រមនេះទុកជាបានការពេញទាំងមូល។ ទាក់ទងផែនទីក្បាលដីពីលើអាកាសនេះ គឺសាលាដំបូងរាជធានីភ្នំពេញ បានធ្វើលិខិតស្នើសុំឲ្យខាងមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ ផ្តល់ជូន



Scanned with CamScanner

មកតុលាការ ហើយរាល់ឯកសារដែលភាគីខ្លួនបានទទួល គឺខាងជំនាញបានផ្តល់ជូនមកតុលាការទេ មិនមែនកូនក្តីខ្លួនបានមកពីណាដោយឯកឯងដាក់ចូលសំណុំរឿងទេ។

-មេធាវី [redacted] តំណាងដោយអណត្តិឲ្យឈ្មោះ [redacted] សុម៉ាលី បានថ្លែងថា ខ្លួនពុំមានអ្វីបន្ថែមទេ ឯកភាពតាមមេធាវីសហភាគដែលបានថ្លែងរួចហើយ។

២-**ការអះអាងរបស់ចុងចម្លើយ**

-ឈ្មោះ [redacted] ស៊ូអៀង "អវត្តមាន"

-មេធាវី ណាច ទ្រី តំណាងដោយអណត្តិឲ្យឈ្មោះ [redacted] ស៊ូអៀង បានថ្លែងថា ខ្លួនប្តឹងឧទ្ធរណ៍ដោយមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០២ក្រ២-ឃ- ចុះថ្ងៃទី ១០-០២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយចំណុចមួយចំនួនដូចខាងក្រោម:

-ចំណុចទី១ សាលាដំបូងមិនបានអនុវត្តតាមនីតិវិធីក្រមរដ្ឋប្បវេណីទេ ក្នុងសំណុំរឿងនេះគាត់មិនបានបង្គាប់ឲ្យគូក្តីដើម្បីដាក់ជូនពិនិត្យភស្តុតាង ស្រាប់តែគាត់លើកមកធ្វើការជំនុំជម្រះតែម្តង ហើយខ្លួនបានសំណូមពរនៅពេលសវនាការ បែរជាក្រុមប្រឹក្សាគាត់ថា ក្រុមប្រឹក្សាមានសិទ្ធិ បើក្រុមប្រឹក្សាមានសិទ្ធិក្រមត្រូវទាត់ចោលហើយ ជាចំណុចសំខាន់ក្នុងការមោឃភាពនៃនីតិវិធីនេះ។

-ចំណុចទី២ រាល់លិខិតស្នាមដែលភាគីដើមបណ្តឹង ឬ ម្ចាស់បំណុលដាក់ក្នុងពាក្យបណ្តឹងបន្ថែម ឬ ឯកសារផ្សេងៗ ដែលមន្ត្រីជំនាញបានបញ្ជាក់មក គឺក្រុមប្រឹក្សាមិនបានបញ្ជូនមកឲ្យចុងចម្លើយ ឬចុងបណ្តឹងទេ ការជំនុំជម្រះដោយអាថិកំបាំង សូម្បីតែមេធាវីមិនបានឲ្យដឹងដែរ ដែលក្នុងនីតិវិធីនេះខ្លួនមិនដែលជួបប្រទះទេ។

-ចំណុចទី៣ ខ្លួនបានទទួចសុំឲ្យដើមបណ្តឹងដាក់ច្បាប់ដើមដើម្បីឲ្យគូភាគីពិនិត្យ តែក្នុងសំណុំរឿងមានតែថតចម្លងអត់មានច្បាប់ដើមឲ្យខ្លួនមើលទេ។

-ចំណុចទី៤ ខ្លួនសុំបញ្ជាក់ថា ដីដែលមានម្ចាស់កម្មសិទ្ធិដើមឈ្មោះ [redacted] សារុធ ធ្វើអំណោយតមកឲ្យអ្នកស្រី [redacted] សុម៉ាលី ខ្លួនសួរថា តើគាត់មានផ្តិតមេដៃកំណត់ព្រំដីឲ្យគេទេ? ហើយនៅពេលសវនាការគាត់ឆ្លើយមិនរួចទេ គាត់បែរជាឆ្លើយថា គេពន្យ៉ះឲ្យផ្តិតចេះតែផ្តិតទៅ តែគាត់ជានីតិជន មិនអនីតិជនទេ ហើយនេះជាកំណត់បង្ហាញផ្តិតមេដៃរបស់ឈ្មោះ [redacted] សារុធ បានកំណត់ព្រំឡាស់ណាស់ ហើយកូនក្តីខ្លួនបានវាស់ព្រំតាំងពីគណៈកម្មការចុះវាស់ផ្តល់ប័ណ្ណកម្មសិទ្ធិអត់មានដែលសើរើព្រំ ដែកព្រំ បង្គោលឡាក់។

-ចំណុចទី៥ ការសុំបើកផ្លូវតុលាការបានចុះទៅហើយ កូនក្តីខ្លួនមិនជំទាស់ទេ សួរថាតើមានភ្លីភ្លោះទេទំហំ១០ម ការលើកឡើងរបស់ដើមបណ្តឹងគឺ អត់មាន អត់ឃើញ ដែលមានតែប្រឡាយជាប់របងរបស់ជំទាវ [redacted] ឈាវហ្វ ឥឡូវគេធ្វើរបងឃាំងហើយ ម៉េចមិនសុំបើកផ្លូវផងបើកតែទំហំ៥ម ចេញបានហើយៗ ចំណុចដែលសុំបើកផ្លូវបើកយ៉ាងម៉េច ចំណែកផ្លូវ២០០៤ ចូលមកចម្ងាយ៥០ម ដែលកូនក្តីខ្លួនបានទិញពីប្រជាពលរដ្ឋដោយមានលិខិតលក់-ទិញត្រឹមត្រូវ អាជ្ញាធរបានបញ្ជាក់ត្រឹមត្រូវ ហើយតុលាការបានចុះទៅមើលទៀតតើដីមានទំហំ១០ម ឬអត់ ដែលផ្លូវមានតែទំហំ៦ម ហើយគាត់សម្រេចដល់ទំហំ ១០ម តើ១០មនោះបានមកពីណាប្លន់គេ ដល់ផ្លូវបេតុងធ្វើហើយ គាត់សម្រេចថាឲ្យបើក១០ម តាមការសុំរបស់ដើមបណ្តឹងបានមកពីណា និងធ្វើផ្លូវបេតុងមិនបានបិទផ្លូវមិនឲ្យដើមបណ្តឹងចូលទេ គឺ



Scanned with CamScanner

ការចេញចូលដោយសេរី ព្រោះជាមជ្ឈមណ្ឌលកីឡាខ្នាតអន្តរជាតិ ប៉ុន្តែឲ្យវាយរបងព្រំចោលគឺមិនអាចទេ ព្រោះនៅពេលផ្តិមេដៃធ្វើប្លង់ខ្លួនបានផ្តិតឲ្យគេជំនាន់លោក [redacted] សាវុធ មិនមែនផ្តិតជំនាន់លោកស្រី [redacted] សុម៉ាលី ទេ ហើយដល់ពេលផ្ទេរសិទ្ធិឲ្យ [redacted] សុម៉ាលី បែរជាប្តឹងសុំឲ្យគេបើកច្រក ចុះហេតុអ្វីតាំងពីឆ្នាំ១៩៩៦ គាត់គ្រប់គ្រងមិនបើកច្រក។

-ចំណុចទី៦ រក្សាការពារលោក [redacted] សុវណ្ណ បានធ្វើទៅមេឃុំ-ភូមិ បញ្ជាក់ថា គ្មានផ្លូវទេ ហើយផ្លូវបីម៉ែត្រតូចចង្អៀតកូនក្តីខ្លួនបានទិញពីប្រជាពលរដ្ឋ មិនមានដើមបណ្តឹងណាទិញបានមួយរៀលទេ បែរជាតុលាការដើមបណ្តឹងជូយ១/៣ នៃការសាងសង់ តែបើមានចំណែកណាមួយក្នុងការទិញដីរាប់ម៉ឺននោះកូនក្តីខ្លួនក៏សម្បទានដែរ បែរជាតុលាការសម្រេចចេញ១/៣ ចាក់បេតុង កូនក្តីខ្លួនចោលក៏បានដែរ តែសំខាន់រឿងដែលទិញដីនោះតុលាការអត់មើល ហើយថាជាសិទ្ធិរបស់ចៅក្រម តែបើប្តឹងក៏ជាសិទ្ធិរបស់ភាគីដែរ។ តុលាការសម្រេចនេះអត់បានមើល ស្តាប់ភាគីម្ខាងដាក់អំណះអំណាងទេ គាត់យកសាក្សីចូលធ្វើទាហានអាយុ១៨ឆ្នាំ មកជាសាក្សីផ្លូវការ។

-ចំណុចទី៧ ឯកសាររបស់ជំនាញដែលធ្វើមក ដែលគាត់ដាក់ទាំងប៉ុន្មានខ្លួនទើបតែបានពេលសវនាការទេ នីតិវិធីក្នុងការផ្តល់ជាសិទ្ធិរបស់គាត់ តែក្រមបានថែង ត្រូវដាក់ជូនភាគីពិនិត្យភស្តុតាង ហើយខ្លួនជាមេធាវីតាំងពីដំបូង។ ខ្លួនសុំឲ្យក្រុមប្រឹក្សាសម្រេចលុបចោលសាលក្រមរបស់សាលាដំបូងចោលជាអសារបង់។ ខ្លួនសុំបញ្ជាក់ថា នៅថ្ងៃជម្រះចុងក្រោយខ្លួនបានចូលរួម ការអះអាងរបស់មេធាវីសហភាគីដែលបានបញ្ជាក់អំពីបញ្ហានីតិវិធីត្រឹមត្រូវ គឺជាការលើឡើងរបស់ភាគីគាត់ ប៉ុន្តែខ្លួនបានលើកដើមមកហើយ ការចូលរួមជាមេធាវីតំណាងដោយអណត្តិមកនេះ ខ្លួនជាអ្នកដាក់សំណុំរឿងមុនគេបង្អស់ សូម្បីសហភាគាត់ធ្វើក្រោយខ្លួនដែរបានទទួលដីកាពីតុលាការ ហេតុអីបានជាខ្លួនជាមេធាវីមិនបានទទួលដីកាពីតុលាការ គ្រាន់តែសួរប៉ុណ្ណឹងទេ ហើយរឿងគាត់បកស្រាយត្រឹមត្រូវឬ មិនត្រឹមត្រូវជាសិទ្ធិរបស់ចៅក្រមទេ ហើយមេធាវីដែលបាទទួលដីកាជាមេធាវីក្រុមផ្សេងគ្នាមិនអាចដាក់តែមួយបានទេ សូមឲ្យក្រុមប្រឹក្សាពិចារណា។ ការលើកឡើងបញ្ហាប្លង់អាកាស តើយើងយកសុរិយោដីជាគោល ក៏ចេះតែយកប្លង់អាកាសថតមកជាគោល ព្រោះក្នុងរឿងនេះឯកសារជាគោល គឺឯកសារខាងសុរិយោដីស៊ីញ៉េដោយ [redacted] ឬទ្ធីសែន ទើបជាប្លង់ត្រឹមត្រូវមិនអាចសហភាគាយកប្លង់អាកាសមកមើលទេ តើអ្នកណាបញ្ជាក់ថាប្លង់អាកាសត្រឹមត្រូវ។ ការចាក់ដីបំពេញសូមឲ្យក្រុមប្រឹក្សាមើលពាក្យបណ្តឹងផ្លូវឆ្លោះទទឹង១០ម តើដីស្រែមានទទឹង១០ម ទេ ព្រោះចៅសង្កាត់គេបញ្ជាក់ហើយថាគ្មានទេ តើយើងជឿលើសាក្សីរបស់ដើមបណ្តឹងដាក់មកនិយាយ តើមានយកសាក្សីដែលកូនក្តីខ្លួនបានទិញមានយកមកនិយាយដែរទេ ហើយសាក្សីគាត់មានអាយុ១៥ឆ្នាំ ចូលធ្វើទាយានទៅនាយកដ្ឋានបច្ចេកទេសមានសក្តិ៣ហើយ ហើយសាក្សីឈ្មោះ [redacted] សុផាន នេះត្រូវជាក្មួយរបស់ឈ្មោះ [redacted] សុផាន ដែលកូនក្តីខ្លួនបានទិញដីពីពូរបស់វា និងបានទិញ៣ម ពីឈ្មោះ [redacted] សុផានី ទៀត ដែលម្តងថាមានផ្លូវម្តងថាអត់ផ្លូវ តើសាក្សីនេះចាត់ទុកជាបានការទេ។ គាត់បានយកលោក [redacted] សាវុធ ជាម្ចាស់ដីផ្ទេរសិទ្ធិឲ្យបងស្រីគាត់ ហើយគាត់ធ្វើជាសាក្សីសួរថាគាត់បានដីមកពីណា គាត់



Scanned with CamScanner

ថាមានគណៈកម្មការចែកៗ ម្ដេចផ្ដិតមេដៃឲ្យគេធ្វើអី ហើយគាត់ថាគេឲ្យផ្ដិតចេះតែផ្ដិតទៅ។

## សំអាងហេតុ

១-បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២៧-៣-២០១២ របស់លោក ទូច ឆាយ ជាមេធាវីតំណាងដោយអណត្តិឲ្យភាគីចុងចម្លើយឈ្មោះ [redacted] ស៊ូអៀង ប្ដឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ០២ក្រ២-ឃ-ចុះថ្ងៃទី ១០-០២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន។

២-ផ្អែកតាមសេចក្ដីថ្លែងការការណ៍របស់មេធាវីតំណាងដោយអណត្តិឲ្យភាគីដើមចោទបានបញ្ជាក់ថា សុំឲ្យភាគីចុងចម្លើយបើកផ្លូវចេញ-ចូលមានទំហំទទឹង១០ម៉ែត្រ នៅជាប់ព្រំដីផ្នែកខាងលិចភ្ជាប់ទៅផ្លូវបេតុងរបស់ភាគីចុងចម្លើយ ដែលបច្ចុប្បន្នមានស្រាប់ទៅផ្លូវលេខ ២០០៤ ជំនួសភ្លឺភ្លោះទំហំ១០ម៉ែត្រ ស្ថិតនៅជាប់ព្រំដីផ្នែកខាងកើតជាផ្លូវសំរាប់ដើរចេញចូលក្នុងដីរបស់ខ្លួន។ ព្រោះថាពេលកន្លងមកភាគីចុងចម្លើយបានចាក់ដីបំពេញ និងសាងសង់សំណង់ផ្សេងៗ អស់ទៅហើយ មិនអាចចេញចូលដូចមុនឡើយ។

៣-មេធាវីតំណាងឲ្យភាគីចុងចម្លើយបានបញ្ជាក់ថាតុលាការថ្នាក់ក្រោមពុំបានបញ្ជូនលិខិតបង្គាប់ឲ្យជូនសំអាងមកឲ្យខ្លួនជាមេធាវីឡើយ សុំឲ្យតុលាការពិចារណា។ ម៉្យាងទៀតខ្លួនស្នើសុំឲ្យភាគីដើមចោទផ្ដល់ឯកសារលិខិតធ្វើអំណោយផ្ដាច់ ចុះថ្ងៃទី១៧-៧-២០០៦ ជាច្បាប់ដើម ដើម្បីពិនិត្យពុំឃើញមានការផ្ដល់ឡើយ។ សុំឲ្យតុលាការច្រានចោលការទាមទាររបស់ភាគីដើមចោទ ដោយហេតុថាដីនេះកូនក្ដីខ្លួនបានទិញពីម្ចាស់ដើមត្រឹមត្រូវតាមច្បាប់ ហូតដល់មានការចេញប័ណ្ណសាលកប័ត្រក្បាលដី និងសុំច្បាប់សាងសង់ និងមានគំនូសបង្ហាញទីតាំងចុះថ្ងៃទី ១៥-១០-២០០៨ ត្រឹមត្រូវទៀតផង។

៤-ចំពោះដីកាបង្គាប់ឲ្យភាគីផ្ដល់ភស្ដុតាងនេះ គឺមេធាវីសហភាតារបស់ភាគីចុងចម្លើយបានទទួលត្រឹមត្រូវហើយ ដូចមានក្នុងឯកសារបញ្ជាក់ស្រាប់។ រីឯលិខិតធ្វើអំណោយផ្ដាច់ចុះថ្ងៃទី ១៧-៧-២០០៦ ច្បាប់ដើម តាមការបញ្ជាក់របស់មេធាវីតំណាងឲ្យភាគីដើមចោទថា បានប្រគល់ឲ្យទៅតុលាការរួចហើយៗ តុលាការបានថតចម្លងទុកក្នុងសំណុំរឿងរួចហើយដែរ។

៥-ផ្អែកតាមការបញ្ជាក់របស់ភាគីដើមចោទ និងសាក្សី និងឯកសារលិខិតលេខ ១១៦៦ ដនសសបទ ចុះថ្ងៃទី ៣០-១១-២០១១ និងប្លង់បង្ហាញទីតាំងដីទំនាស់រវាងឈ្មោះ [redacted] សុម៉ាលី និងឈ្មោះ [redacted] ស៊ូអៀង លេខ២៦/១១បទ ចុះថ្ងៃទី ១១-១០-២០១១ របស់ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ បញ្ជាក់ឲ្យឃើញថា ភាគីចុងចម្លើយបានធ្វើផ្លូវបេតុងជាប់ព្រំដីផ្នែកខាងលិចដីរបស់ភាគីដើមចោទសំរាប់ចេញចូលទៅកាន់ផ្លូវលេខ ២០០៤ "សទ្បា" ប្រាកដមែន។ ម្យ៉ាងទៀតតាមការបញ្ជាក់ឃើញថា ដីរបស់ភាគីឈ្មោះ [redacted] សុម៉ាលី មានទំហំ ៣៥៩៨ម$^2$ ប៉ុណ្ណោះ។ ដូចនេះមានន័យថា ដីកម្មសិទ្ធិរបស់ភាគីដើមចោទគឺបានបាត់បង់អស់ចំនួន ៤០២ម$^2$ ប្រាកដមែន វាគ្រាន់តែខុសគ្នាចំពោះទំហំដី នៃការទាមទារតែប៉ុណ្ណោះ ដូចនេះតុលាការ គប្បីពិចារណាតាមសេចក្ដីបញ្ជាក់



Scanned with CamScanner

និងប្លង់ទីតាំងដីទំនាស់ដែលធ្វើឡើងដោយមន្ត្រីស្ថាប័នជំនាញខាងលើជាមូលដ្ឋានក្នុងការសម្រេចសេចក្តី។

៦-រឿងក្តីនេះសាលាដំបូងបានលើកយកសំអាងហេតុមកបញ្ជាក់មានលក្ខណៈត្រឹមត្រូវហើយ ហេតុដូច្នេះសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ឯកភាពតាមសំអាងហេតុនេះទាំងស្រុង ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតឡើយ។

៧-សាលក្រមរដ្ឋប្បវេណីលេខ ០២ក្រ២"ឃ" ចុះថ្ងៃទី ១០-០២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ គួរតម្កល់ទុកជាបានការដដែល។

## សេចក្តីសម្រេចបញ្ចប់

១-ច្រានចោលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៧-៣-២០១២ របស់លោក [redacted] ឆាយ ជាមេធាវីតំណាងដោយអណត្តិឲ្យភាគីចុងចម្លើយឈ្មោះ [redacted] ស៊ូអៀង។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០២ក្រ២ "ឃ" ចុះថ្ងៃទី ១០-០២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ០៤-៩-២០១២។

-បើកផ្លូវប្តឹងសាទុក្ខរយៈពេល ០១ខែ ក្រោយពីបានទទួលលិខិតជូនដំណឹងអំពីសាលដីកានេះ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

សាលាឧទ្ធរណ៍ ថ្ងៃទី ២៤ ខែ ១០ ឆ្នាំ ២០១២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]